សំណួរដែលបានសួរជាញឹកញាប់

ការចាក់ថ្នាំបង្ការក្នុងអំឡុងជំងឺ COVID-19 គឺចាំបាច់សម្រាប់សុខភាពកូនរបស់អ្នក

1. តើកូនរបស់ខ្ញុំគួរទទួលការចាក់ថ្នាំបង្ការខណៈពេលដែលមានករណីជំងឺ COVID-19 នៅក្នុងខោនធី Los Angeles ដែរឬទេ?

- ត្រឹមត្រូវ ការចាក់ថ្នាំបង្ការ និងការពិនិត្យសុខភាពកុមារមានសារៈសំខាន់ និងជួយរក្សាឲ្យកូនរបស់អ្នកមានសុវត្ថិភាព និងមានសុខភាពល្អ ជាពិសេសសម្រាប់កុមារអាយុក្រោមពីរឆ្នាំ។
- ការចាក់ថ្នាំបង្ការការពារកូនអ្នកពីជំងឺធ្ងន់ធ្ងរ និងគ្រោះថ្នាក់ ដូចជាជំងឺកញ្ជើល ជំងឺក្រឡទែន ជំងឺក្អកមាន់ (ក្អកមាន់) និងគ្រុនផ្តាសាយធំ។
- បើសិនជាកូនរបស់អ្នកមិនបានទទួលការចាក់ថ្នាំបង្ការរបស់ខ្លួន ចូរទៅជួបអ្នកផ្តល់សេវាថែទាំសុខភាពឲ្យបានឆាប់បំផុតដើម្បីទទួលការចាក់ថ្នាំបង្ការដែលពួកគេត្រូវការឲ្យបានទាន់ពេលវេលា។
- សម្រាប់បញ្ជីនៃការចាក់ថ្នាំបង្ការដែលកុមារត្រូវការ ចូរចូលទៅកាន់៖ www.cdc.gov/vaccines/schedules/index.html.

2. តើធ្វើដូចម្តេចបើខ្ញុំមានការព្រួយបារម្ភអំពីការយកកូនរបស់ខ្ញុំទៅទទួលការចាក់ថ្នាំបង្ការក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល?

- នេះគឺជាការព្រួយបារម្ភធម្មតា។ ការិយាល័យថែទាំសុខភាព ដោយរាប់បញ្ចូលទាំងគ្លីនិក និងឱសថស្ថានកំពុងធ្វើសកម្មភាពដើម្បីប្រាកដថាអ្នកទៅជួបបានដោយសុវត្ថិភាព។
- ចូរទូរសព្ទមុនពេលទៅជួប ដើម្បីសាកសួរពីរបៀបដែលពួកគេរក្សាឲ្យអ្នកជំងឺមានសុវត្ថិភាព និងជំហានផ្សេងៗដែលអ្នកចាំបាច់ត្រូវធ្វើ។
- មនុស្សគ្រប់គ្នាដែលចូលក្នុងការិយាល័យគ្រូពេទ្យ គ្លីនិក ឬឱសថស្ថានត្រូវតែពាក់របាំងមុខលើកលែងតែកុមារអាយុក្រោម 2 ឆ្នាំ នរណាម្នាក់ដែលមានបញ្ហាក្នុងការដកដង្ហើម ឬនរណាម្នាក់ដែលមិនអាចដោះរបាំងមុខដោយខ្លួនឯងបាន។ អ្នកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាមិនត្រូវពាក់ ក៏ត្រូវបានលើកលែងផងដែរ។ កុមារអាយុពី 2-8 ឆ្នាំគួរពាក់ម៉ាស់នៅពេលដែលមានការគ្រប់គ្រងតែប៉ុណ្ណោះ។

3. តើខ្ញុំអាចយកកូនរបស់ខ្ញុំទៅទទួលការចាក់ថ្នាំបង្ការនៅទីណា?

- សម្រាប់បញ្ជីសេវាកម្មចាក់ថ្នាំបង្ការដែលមានតម្លៃថោក ឬឥតគិតថ្លៃ សូមចូលទៅកាន់គេហទំព័រ DPH នៅ៖ publichealth.lacounty.gov/ip/clinics.htm.
- អ្នកក៏អាចទូរសព្ទទៅខ្សែទូរសព្ទព័ត៌មានខោនធី Los Angeles តាមរយៈលេខ 2-1-1 ឬចូលទៅកាន់គេហទំព័រ អ្នកស្វែងរកវ៉ាក់សាំងនៅ vaccinefinder.org។



4. តើមានការចាក់ថ្នាំបង្ការដើម្បីការពារកូន និងគ្រួសាររបស់ខ្ញុំពីជំងឺ COVID-19 ដែរឬទេ?

ទេ ប៉ុន្តែការទទួលការចាក់ថ្នាំបង្ការជាទម្លាប់ដូចជាវ៉ាក់សាំងជំងឺគ្រុនផ្តាសាយធំ វ៉ាក់សាំងសម្រាប់ជំងឺកញ្ជើល ឬក្អកមាន់អាចជួយការពារកូនរបស់អ្នកពីជំងឺផ្សេងៗទៀត។

CDCP-IP-0025-01 (6/23/20)